ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម
នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ
នៃប្រទេសជប៉ុន


# រឿងជោគជ័យនៃមុខរបរទីផ្សារជ្រូក សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង




រៀបចំដោយ៖ គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

ឧបត្ថម្ភដោយ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

ខែកក្កដា ឆ្នាំ២០១៥


រឿងជោគជ័យទី ១

**រឿងជោគជ័យទី ១**

**រឿងជោគជ័យនៃមុខរបរទីផ្សារជ្រូក**

**សហគមន៍សិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង**

បោះពុម្ពផ្សាយ៖ ខែកក្កដា ឆ្នាំ២០១៥

បោះពុម្ពដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម (MAFF)
គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

អស័យដ្ឋាន៖ # ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់ ៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ
ប្រទេសកម្ពុជា

ទូរស័ព្ទ៖ (០២៣) ៨៨៣ ៤២៧ ទូរសារ៖ (០២៣) ៨៨៣ ៤២៧

© គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

# មាតិការ


សេចក្ដីថ្លែងអំណរគុណ

I. សេចក្ដីផ្ដើម ........ ១

១. តើគម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញគឺជាអ្វី? ........ ១

២. គោលបំណងនៃការបោះពុម្ពរឿងជោគជ័យ ........ ១

៣. មូលហេតុនៃការជ្រើសរើសសហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង ........ ២

៤. និយមន័យនៃមុខរបរទីផ្សាររបស់សហគមន៍កសិកម្ម ........ ២

II. រឿងជោគជ័យ ........ ៣

១. ប្រវត្តិរបស់សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង ........ ៣

២. សង្ខេបស្ថានភាពទូទៅរបស់សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង ........ ៤

៣. ស្ថានភាពនៃមុខរបរទីផ្សារជ្រូកនៅក្នុងសហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង ........ ៥

៤. របៀបទំនាក់ទំនងរកឈ្មួញរបស់សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង ........ ៧

៥. របៀបកំណត់តម្លៃទិញជ្រូកសាច់ពីសមាជិក ........ ៧

៦. ផែនការនៅពេលអនាគត ........ ៨

# សេចក្ដីថ្លែងអំណរគុណ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមថ្លែងអំណរគុណដល់សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង និងសហការីទាំងអស់ ជាពិសេស លោក **នាង ចន្ថា** ប្រធានសហគមន៍កសិកម្មនេះដែលបានចំណាយពេលវេលាផ្តល់បទសំភាសន៍ និងព័ត៌មានដ៏មានតម្លៃដល់ក្រុមការងារនៃគម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញដើម្បីចងក្រងរឿងជោគជ័យនៃមុខរបរទីផ្សារជ្រូករបស់ "សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង" ដែលជារឿងជោគជ័យទី១ នៃបណ្តារឿងជោគជ័យផ្សេងទៀត។

## I. សេចក្តីផ្តើម

### ១. តើគម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញគឺជាអ្វី?

ក្រោមការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុពីជំនួយផ្លូវការរបស់រដ្ឋាភិបាលជប៉ុន (Official Development Assistant, ODA) តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (Japan International Cooperation Agency, JICA) គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (Project for Establishing Business-oriented Agricultural Cooperative Models, BPAC) ត្រូវបានបង្កើត និងអនុវត្តដោយអគ្គនាយកដ្ឋានកសិកម្ម (General Directorate of Agriculture, GDA) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture, Forestry and Fisheries, MAFF) ដែលសហការជាមួយអង្គការ JICA នៅកម្ពុជា។ គម្រោងកំពុងអនុវត្តនៅក្នុងខេត្តគោលដៅចំនួន៤ ដែលរួមមាន ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពង់ចាម និងខេត្តស្វាយរៀង សម្រាប់រយៈពេលប្រាំឆ្នាំ ដោយគិតចាប់ពីខែឧសភា ឆ្នាំ២០១៤ រហូតដល់ខែឧសភា ឆ្នាំ២០១៩។

គោលបំណងរួមនៃគម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញគឺដើម្បីផ្សព្វផ្សាយសហគមន៍កសិកម្មគំរូដែលប្រកបមុខរបរមានចែងនៅក្នុងច្បាប់ស្តីពីសហគមន៍កសិកម្មដូចជាមុខរបរឥណទាន មុខរបរផ្គត់ផ្គង់ និងមុខរបរទីផ្សារជាដើម ទៅដល់សហគមន៍កសិកម្មដទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ២. គោលបំណងនៃការបោះពុម្ពរឿងជោគជ័យ

គោលបំណងរបស់រឿងជោគជ័យនេះគឺដើម្បីស្វែងរកសហគមន៍កសិកម្មដែលមានភាពជោគជ័យលើការប្រកបមុខរបរនានាដូចជាមុខរបរទីផ្សារ ផ្គត់ផ្គង់ និងឥណទាន និងការអភិវឌ្ឍន៍រចនាសម្ព័ន្ធនិងការគ្រប់គ្រងរបស់សហគមន៍កសិកម្មនៅក្នុងប្រទេស ដើម្បីផ្សព្វផ្សាយព័ត៌មានទាំងនោះទៅដល់សហគមន៍សិកម្មផ្សេងទៀតសម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍន៍សហគមន៍កសិកម្មរបស់ខ្លួន ។

នេះគឺជារឿងជោគជ័យទី១របស់គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញដែលបានបោះពុម្ពផ្សព្វផ្សាយ។

## ៣. មូលហេតុនៃការជ្រើសរើសសហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង

សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង (សហគមន៍កសិកម្មចិញ្ចឹមជ្រូក) បានបង្កើតឡើងនៅឆ្នាំ ២០០៩។ ដោយសារសហគមន៍កសិកម្មនេះទទួលបានជោគជ័យក្នុងការប្រកបមុខរបរចិញ្ចឹមជ្រូក ហើយចំនួនសមាជិកនិងភាគហ៊ុនមានការកើនឡើង ហេតុដូច្នេះហើយបានជាគម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញបានជ្រើសរើសសហគមន៍កសិកម្មនេះដើម្បីសរសេរជារឿងជោគជ័យដំបូងបង្អស់។

## ៤. និយមន័យនៃមុខរបរទីផ្សាររបស់សហគមន៍កសិកម្ម

មុខរបរទីផ្សារគឺជាមុខជំនួញមួយប្រភេទរបស់សហគមន៍កសិកម្មដែលប្រមូលទិញនូវផលិតផលកសិកម្មដូចជា ស្រូវ គ្រាប់ធញ្ញជាតិផ្សេងៗ បន្លែ ផ្លែឈើ និងសត្វ ពីសមាជិករបស់ខ្លួនដើម្បីលក់ទៅឱ្យឈ្មួញ ទីផ្សារ និងអ្នកបរិភោគ។ ផ្ទុយទៅវិញ នៅពេលដែលសហគមន៍កសិកម្មទិញធាតុចូលកសិកម្មដូចជាជី គ្រាប់ពូជ និងសំភារៈកសិកម្ម ជាដើមពីខាងក្រៅរួចលក់ទៅឱ្យសមាជិក គឺជាមុខរបរផ្គត់ផ្គង់។

## II. រឿងជោគជ័យ

### ១. ប្រវត្តិរបស់សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង



រូបភាព ១: លោក នាង ចន្ថា ប្រធានសហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង

ចាប់តាំងពីឆ្នាំ២០០៣ រហូតមកដល់ពេលបច្ចុប្បន្ន លោក **នាង ចន្ថា** ជាប្រធាន**ផ្សារជីភូ** ដែលមានទីតាំងស្ថិតនៅក្រុងបាវិត ខេត្តស្វាយរៀង។ ក្រោមការគ្រប់គ្រងផ្សារ គាត់បានឃើញបន្លែសេសសល់ចោលនៅក្នុងផ្សារជាច្រើន ពេលនោះគាត់គិតថាប្រសិនជាយកទៅអោយជ្រូកស៊ីគឺពិតជាឆាប់ធំធាត់និងមិនចាំបាច់ចំណាយប្រាក់ទិញចំណីច្រើនពេកទេ។ បន្ទាប់មកគាត់ក៏ចាប់ផ្តើមចិញ្ចឹមជ្រូកចំនួន២ក្បាលប៉ុណ្ណោះជាលក្ខណៈគ្រួសារដោយផ្តល់ចំណីដូចជា កាកសំណល់ផ្ទះបាយ កន្ទក់ និងបន្លែដែលសល់យកពីក្នុងផ្សារ។ ក្រោយពីគាត់ចិញ្ចឹមជ្រូកបានធំធាត់ហើយ គាត់បានលក់ជ្រូកសាច់ (ជ្រូករស់) ទាំងនេះជាលើកដំបូងនៅក្នុងឆ្នាំ២០០៣ ទៅឱ្យអ្នកទិញជ្រូកដែលជិះម៉ូតូដើរទិញជ្រូកនៅតាមភូមិយកទៅកាប់សាច់ខ្លួនឯង។

ដោយមើលឃើញមុខរបរនេះទទួលបានផលចំណេញច្រើន គាត់បានពង្រីកមុខរបរនេះពីមួយឆ្នាំទៅមួយឆ្នាំដោយបានបង្កើនការចិញ្ចឹមជ្រូករហូតដល់ ១០០ក្បាល ព្រមទាំងបានទិញមេជ្រូកពីវៀតណាមចំនួន ២ក្បាល ដើម្បីធ្វើជាមេពូជ នៅក្នុងឆ្នាំ២០០៥។ ពេលលក់ជ្រូកសាច់ គាត់បានទាក់ទងជាមួយឈ្មួញដែលចុះទិញជ្រូកតាមភូមិអំពីព័ត៌មាន និងលេខទូរស័ព្ទរបស់ឈ្មួញផ្សេងទៀតដែលទិញជ្រូកជាច្រើនក្បាលដើម្បីដឹកយកទៅលក់នៅឯភ្នំពេញ។ បន្ទាប់មក គាត់បានទូរស័ព្ទទៅឈ្មួញទិញជ្រូកទាំងនោះដើម្បីចរចារអំពីតម្លៃទិញជ្រូកសាច់។ ក្រោយពីឯកភាពគ្នារឿងតម្លៃហើយ ឈ្មួញបានចុះមកទិញជ្រូកសាច់នោះនៅកសិដ្ឋានរបស់គាត់ដោយថ្លឹងជ្រូក ទូទាត់ប្រាក់ និងលើកដាក់រថយន្ត។

ដោយសារលោក **នាង ចន្ថា** គឺជាប្រធានផ្សារជីភូ និងជាអ្នកចិញ្ចឹមជ្រូក អង្គការ USAID បានអញ្ជើញគាត់ទៅចូលរួមទស្សនៈកិច្ចសិក្សានានានៅក្រៅប្រទេស ដូចជាប្រទេសថៃ វៀតណាម ភីលីពីន និងអាមេរិក ដើម្បីរៀនសូត្រពីរបៀបគ្រប់គ្រងផ្សារ និងបច្ចេកទេសចិញ្ចឹមជ្រូក។ ក្រោយពេលត្រឡប់មកពីទស្សនៈកិច្ចសិក្សាវិញ គាត់ក៏បានពង្រីក

មុខរបរចិញ្ចឹមជ្រូករបស់គាត់បន្ថែមទៀត តាមបច្ចេកទេសនិងបទពិសោធន៍ដែលគាត់ទទួលបានពីទស្សនៈកិច្ចសិក្សានោះ។

នៅឆ្នាំ ២០០៩ ដោយទទួលបានការគាំទ្រពីមន្ទីរកសិកម្មខេត្ត និងអង្គការ USAID គាត់បានបង្កើតសហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀងដែលមានសមាជិកចំនួន ៣០នាក់ ក្នុងនោះមានស្ត្រីចំនួន ៧នាក់ ដើម្បីប្រកបមុខរបរឥណទាន និងផ្តល់សេវាកម្មបច្ចេកទេសចិញ្ចឹមជ្រូកដល់សមាជិក ហើយគាត់បានជាប់ឆ្នោតជាប្រធានសហគមន៍កសិកម្មនេះដំបូងបង្អស់។ បន្ទាប់មក គាត់បានចូលរួមសិក្ខាសាលានៅក្នុងទីក្រុងភ្នំពេញស្តីពីសង្វាក់ផលិតកម្មជ្រូកដែលឧបត្ថម្ភដោយអង្គការ USAID។ គោលបំណងរបស់សិក្ខាសាលាគឺដើម្បីណែនាំអំពីផលិតកម្មនិងទីផ្សារជ្រូក។ នៅក្នុងសិក្ខាសាលានោះ គាត់បានស្គាល់សិក្ខាកាមមួយចំនួនដូចជា តំណាងអ្នកកាប់ជ្រូកធំៗនៅភ្នំពេញ អ្នកចែកចាយជ្រូកនៅតាមបណ្តាខេត្តនានា អ្នកចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ (កសិករ) និងក្រុមហ៊ុននាំចូលជ្រូកពីប្រទេសថៃ។ ក្នុងឱកាសនោះគាត់ក៏បានទទួលឯកសារមួយចំនួនដូចជា នាមប័ណ្ណ និងសៀវភៅទំនាក់-ទំនងដែលរៀបរាប់ពីឈ្មោះក្រុមហ៊ុនលក់ចំណីសត្វ ភ្នាក់ងារទិញ/លក់ជ្រូក រោងម៉ាស៊ីនស្រូវ និងហាងលក់វត្ថុធាតុដើមសម្រាប់ផលិតចំណីសត្វមួយចំនួន។

ចំពោះការលក់ជ្រូកវិញ នៅដើមឆ្នាំ២០១០ សហគមន៍កសិកម្មចិញ្ចឹមជ្រូកបានទាក់ទងជាមួយឈ្មួញទិញជ្រូកនៅក្នុងទីក្រុងភ្នំពេញតាមរយៈទូរស័ព្ទដែលប្រធានសហគមន៍កសិកម្មបានទទួលនៅក្នុងសិក្ខាសាលានោះ។ សហគមន៍កសិកម្មនេះបានចរចារតម្លៃជាមួយឈ្មួញជាច្រើន បន្ទាប់មកបានជ្រើសរើសឈ្មួញទិញជ្រូកម្នាក់។ សហគមន៍កសិកម្មចិញ្ចឹមជ្រូកបានទិញជ្រូកសាច់លើកដំបូងពីសមាជិកចំនួន៤០ក្បាល ក្នុងតម្លៃពី ៧.៥០០ រៀលក្នុងមួយគីឡូក្រាម ហើយបានលក់ជ្រូកសាច់ទាំងនោះទៅឱ្យឈ្មួញនៅឯទីក្រុងភ្នំពេញក្នុងតម្លៃ ៧.៧០០ រៀលក្នុងមួយគីឡូក្រាម។

## ២. សង្ខេបស្ថានភាពទូទៅរបស់សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង

សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀងបានបង្កើតនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ដែលមានអស័យដ្ឋានស្ថិតនៅភូមិត្រដែត ឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ គោលបំណងរបស់សហគមន៍កសិកម្មនេះគឺរួមគ្នាបង្កើតមុខរបរដើម្បីធ្វើឱ្យជីវភាពកសិករមានភាពល្អប្រសើរឡើង។

រូបភាព-២ ស្លាកសញ្ញារបស់សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង

## ការរីកចំរើននៅក្នុងសហគមន៍កសិកម្មចិញ្ចឹមជ្រូក

| បរិយាយ | ឆ្នាំ២០០៩ | ឆ្នាំ២០១៥ |
|---|---|---|
| ចំនួនមុខរបរ | ១. ឥណទាន<br>២. ផ្តល់សេវាកម្មបច្ចេកទេស ក្នុងការចិញ្ចឹមជ្រូក | ១. ឥណទាន<br>២. ផ្តល់សេវាកម្មបច្ចេកទេស ក្នុងការចិញ្ចឹមជ្រូក<br>៣. ផ្គត់ផ្គង់ចំណីសត្វ<br>៤. ទីផ្សារជ្រូក<br>៥. ផ្គត់ផ្គង់ជី |
| ចំនួនសមាជិក | សរុប ៣០ នាក់ (ស្ត្រី ៧ នាក់) | សរុប ២៥៨ នាក់ (ស្ត្រី ៨៣ នាក់) |
| ប្រាក់សមាជិកភាព | ៥.០០០រៀល/នាក់ | ៥.០០០រៀល/នាក់ |
| ចំនួនភាគហ៊ុន | ៣០ ហ៊ុន | ២៨៦ ហ៊ុន |
| តម្លៃក្នុង១ហ៊ុន | ៤០០.០០០ រៀល | ៤០០.០០០ រៀល |
| ចំនួនប្រាក់ភាគហ៊ុន | ១២.០០០.០០០ រៀល | ១១៤.៤០០.០០០ រៀល |
| ចំនួនសមាជិកចិញ្ចឹមជ្រូក | ៣០ នាក់ | ៨០% នៃសមាជិកសរុប |

## ៣. ស្ថានភាពនៃមុខរបរទីផ្សារជ្រូកនៅក្នុងសហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង

បច្ចុប្បន្ននេះ មានពូជជ្រូកបីប្រភេទដែលសមាជិកកំពុងចិញ្ចឹមដូចជា យក់សៀរ (Yorkshire) សម្បុរស ឌុយរ៉ុក (Durok) សម្បុរត្នោត និងភីត្រៀម (Pitriem) សម្បុរខ្លាឃ្មោក។ សហគមន៍កសិកម្មចិញ្ចឹមជ្រូកនិងសមាជិកនៅមិនទាន់បានគិតគូរអំពីរសជាតិនៃសាច់ជ្រូកនៅឡើយទេ ពួកគាត់ផ្តោតសំខាន់ទៅលើការចិញ្ចឹមជ្រូកឱ្យឆាប់ធំធាត់ និងការផលិតចំណីតែប៉ុណ្ណោះ។

ជាធម្មតា សហគមន៍កសិកម្មចិញ្ចឹមជ្រូកមានរៀបចំកិច្ចប្រជុំប្រចាំខែជាមួយសមាជិក។ តាមរយៈកិច្ចប្រជុំនេះ សហគមន៍កសិកម្មអាចដឹងពីព័ត៌មានទាក់ទងនឹងចំនួនជ្រូកសាច់ដែលសមាជិកចង់លក់។ សហគមន៍កសិកម្មចិញ្ចឹមជ្រូកធ្វើការទិញនិងលក់ជ្រូកសាច់ស្ទើរតែរៀងរាល់ថ្ងៃ។ ប៉ុន្តែនៅក្នុងប្រតិបត្តិការនេះ សហគមន៍កសិកម្មនៅមិនទាន់មានកិច្ចសន្យាណាមួយជាមួយសមាជិកចិញ្ចឹមជ្រូក ឬជាមួយឈ្មួញទិញជ្រូកនៅឡើយទេ។

មុនពេលចុះទិញជ្រូកសាច់នៅតាមផ្ទះ ឬកសិដ្ឋានរបស់សមាជិក សហគមន៍កសិកម្មចិញ្ចឹមជ្រូកបានទូរស័ព្ទទៅឈ្មួញទិញជ្រូកនៅក្រុងបាវិត និងខេត្តស្វាយរៀងដើម្បីចរចារពីតម្លៃនិងដឹងពីចំនួនជ្រូកសាច់ដែលពួកគេត្រូវការ ហើយកំណត់តម្លៃលក់។ បន្ទាប់មក ក្រុមទិញជ្រូកដែលមានមន្ត្រីជាថ្នាក់ដឹកនាំសហគមន៍កសិកម្មចាប់ពី ៥នាក់ឡើងទៅបានចុះទៅទិញជ្រូកសាច់ពីសមាជិកដោយថ្លឹង និងទូទាត់ប្រាក់ជាមួយសមាជិក រួចទើបដឹកទៅឱ្យឈ្មួញទិញជ្រូកតាមការគ្រោងទុកដោយប្រើប្រាស់រថយន្តឈ្នួល។

សហគមន៍កសិកម្មចិញ្ចឹមជ្រូកតែងតែទិញជ្រូកសាច់ពីសមាជិកដោយទូទាត់ប្រាក់ភ្លាមៗ ហើយក៏មិនបន្លំគីឡូដែរ។ រីឯតម្លៃវិញ សហគមន៍កសិកម្មនេះហ៊ានទិញជ្រូកសាច់ក្នុងតម្លៃសមស្របដោយប្រៀបធៀបនឹងតម្លៃទិញជ្រូកសាច់របស់ឈ្មួញផ្សេងៗ។ ជាមធ្យម តម្លៃទិញជ្រូកសាច់របស់សហគមន៍កសិកម្មនេះគឺខ្ពស់ជាងតម្លៃទិញជ្រូកសាច់របស់ឈ្មួញផ្សេងទៀតពី១០០-២០០ រៀលក្នុងមួយគីឡូក្រាម។ ដូច្នេះហើយទើបសមាជិកមានទំនុកចិត្តក្នុងការលក់ជ្រូកសាច់ឱ្យសហគមន៍កសិកម្មនេះ។

ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០១៤ សហគមន៍កសិកម្មចិញ្ចឹមជ្រូកបានផ្អាកការលក់ជ្រូកសាច់ទៅទីក្រុងភ្នំពេញដោយសារតម្លៃជ្រូកសាច់នៅទីក្រុងទាបជាងនៅខេត្តស្វាយរៀង ពីព្រោះនៅភ្នំពេញមានជ្រូកសាច់ច្រើនដែលនាំចូលពីប្រទេសវៀតណាម និងប្រទេសថៃ ។ ម្យ៉ាងវិញទៀត ការផ្គត់ផ្គង់ជ្រូកសាច់នៅក្នុងខេត្តស្វាយរៀងមិនបានគ្រប់គ្រាន់ដោយសារការបរិភោគសាច់ជ្រូកមានការកើនឡើង។ ហេតុដូច្នេះហើយទើបសហគមន៍កសិកម្មនេះលក់ជ្រូកសាច់ឱ្យឈ្មួញនៅក្នុងខេត្តស្វាយរៀងតែប៉ុណ្ណោះ។ នៅពេលបច្ចុប្បន្ននេះ សហគមន៍កសិកម្មចិញ្ចឹមជ្រូកខ្វះខាតថវិការដើម្បីទិញជ្រូកសាច់ពីសមាជិកបន្ថែមទៀតសម្រាប់បំពេញតម្រូវការនៅក្នុងខេត្តឱ្យបានគ្រប់គ្រាន់។

## ៨. របៀបទំនាក់ទំនងរកឈ្មួញរបស់សហគមន៍កសិកម្មចិញ្ចឹមជ្រូកខេត្តស្វាយរៀង

ការស្វែងរកឈ្មួញគឺមានសារៈសំខាន់ណាស់ដើម្បីចាប់ផ្ដើមមុខរបរទីផ្សារ។

ចំពោះមុខរបរទីផ្សារជ្រូក មានឈ្មួញទិញជ្រូកចំនួនពីរប្រភេទគឺឈ្មួញកណ្ដាលនិងឈ្មួញកាប់ជ្រូក។

**របៀបទំនាក់ទំនងជាមួយឈ្មួញ៖** ដំបូងសហគមន៍កសិកម្មចិញ្ចឹមជ្រូកបានស្គាល់ឈ្មួញទិញជ្រូកដែលជិះម៉ូតូដើររកទិញតាមភូមិ។ ឈ្មួញទាំងនោះទិញជ្រូកត្រឹមតែមួយ ឬពីរក្បាលប៉ុណ្ណោះ។ ក្នុងករណីដែលសហគមន៍កសិកម្មនេះត្រូវការលក់ជ្រូកសាច់ច្រើន សហគមន៍កសិកម្មបានទាក់ទងជាមួយឈ្មួញនោះដើម្បីសួរព័ត៌មាននិងលេខទូរស័ព្ទសម្រាប់ទំនាក់ទំនងជាមួយឈ្មួញធំៗដែលទិញជ្រូកសាច់ជាច្រើនក្បាល។ សហគមន៍កសិកម្មចិញ្ចឹមជ្រូកក៏បានស្គាល់ឈ្មួញទិញជ្រូកជាច្រើនទៀតដែរជាពិសេសគឺឈ្មួញនៅទីក្រុងភ្នំពេញតាមរយៈសិក្ខាសាលាដែលឧបត្ថម្ភដោយអង្គការ USAID។ សមាជិកសហគមន៍កសិកម្មនេះមានការប្រមូលផ្ដុំទាំងអ្នកកាប់ជ្រូក អ្នកទិញជ្រូក និងអ្នកចិញ្ចឹមជ្រូកដែលផ្ដល់លក្ខណៈងាយស្រួលក្នុងដំណើរការទីផ្សារជ្រូក។

## ៩. របៀបកំណត់តម្លៃទិញជ្រូកសាច់ពីសមាជិក

សហគមន៍កសិកម្មចិញ្ចឹមជ្រូកបានទាក់ទងជាមួយឈ្មួញទិញជ្រូកតាមទូរស័ព្ទ ហើយសម្រេចតម្លៃលក់ជ្រូកសាច់។ បន្ទាប់មក សហគមន៍កសិកម្មនេះកំណត់តម្លៃទិញជ្រូកសាច់ពីសមាជិកដោយដក ២០០ រៀលក្នុងមួយគីឡូក្រាមពីតម្លៃលក់ជ្រូកសាច់។ គិតត្រឹមខែមិថុនា ឆ្នាំ២០១៥ តម្លៃទិញជ្រូកសាច់ពីសមាជិកគឺប្រហែល ៩.២០០ រៀលក្នុងមួយគីឡូក្រាម ហើយតម្លៃលក់ជ្រូកសាច់ទៅឱ្យឈ្មួញគឺប្រហែល ៩.៤០០ រៀលក្នុងមួយគីឡូក្រាម។ តម្លៃទាំងនេះមានការប្រែប្រួលទៅតាមរដូវកាល។

ក្នុងឆ្នាំ ២០១៤ សហគមន៍កសិកម្មចិញ្ចឹមជ្រូកបានទិញនិងលក់ជ្រូកសាច់ប្រហែល ២២២ ក្បាលក្នុងមួយខែ។



រូបភាព-៣ សហគមន៍កសិកម្មចុះទិញជ្រូកពីសមាជិកនៅតាមផ្ទះនិងកសិដ្ឋានរបស់សមាជិក

## ៦. ផែនការនៅពេលអនាគត

ផែនការនាពេលអនាគតនៃមុខរបរទីផ្សារជ្រូករបស់សហគមន៍កសិកម្មចិញ្ចឹមជ្រូកមានដូចខាងក្រោម៖

- បង្កើតទីសត្វឃាតមួយកន្លែងដែលមានលក្ខណៈស្តង់ដានិងមានអនាម័យដើម្បីចែកចាយសាច់ជ្រូកនៅក្នុងខេត្តស្វាយរៀងដោយសារនៅក្នុងខេត្តនេះមិនទាន់មានទីសត្វឃាតដែលមានលក្ខណៈស្តង់ដានិងមានអនាម័យល្អនៅឡើយទេ។ ម្យ៉ាងទៀតការលក់សាច់ជ្រូកអាចទទួលបានចំណេញច្រើនជាងការលក់ជ្រូកសាច់។
- ពង្រីកមុខរបរទីផ្សារជ្រូកដោយជំរុញឱ្យសមាជិកបង្កើនការចិញ្ចឹមជ្រូកបន្ថែមទៀត និងបង្កើនសមាជិកចិញ្ចឹមជ្រូកថ្មីដោយផ្តល់ប្រាក់កម្ចីដល់គាត់។
- កែលម្អពូជជ្រូកដោយទិញមេជ្រូកថ្មីដើម្បីបានសាច់ច្រើន និងខ្លាញ់តិច។
- បង្កើនភាគហ៊ុនបន្ថែមដើម្បីមានទុនគ្រប់គ្រាន់ក្នុងការទិញជ្រូកសាច់ពីសមាជិក៕

**Series of success story No. 1**

**Success story of Pig Marketing Business**

**Chenh Chem Chrouk Khet Svay Rieng Agricultural Cooperative**

Printed in July 2015

Published by Department of Agricultural Cooperative Promotion of General Directorate for Agriculture (MAFF)

The project for Establishing Business-oriented Agricultural Cooperative Models (BPAC)

Address: # 54B/49F, St. 395-656, Sangkat Toeuk Laak 3, Khan Toul Kok, Phnom Penh, Cambodia

Phone: (023) 883 427, Fax: (023) 883 427

© The project for Establishing Business-oriented Agricultural Cooperative Models